# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ...៤២៨...អនក្រ.បក

## អនុក្រឹត្យ
## ស្ដីពី
## ការធ្វើអនុបយោគ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្ដីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្ដីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- លិខិតលេខ ៦៧៨ សជណ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៥ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ ៦៩៦៧ កសក ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

www.pheakdeylaw.com

## សម្រេច

**មាត្រា១៖**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៦៦០,៩៨៣៧ (ប្រាំមួយរយហុកសិបក្បៀស ប្រាំបួនពាន់ប្រាំបីរយសាមសិបប្រាំពីរ) ហិកតា ដែលមានទីតាំងស្ថិតនៅឃុំភ្នំកុក ស្រុកវើនសៃ ខេត្តរតនគិរី របស់ក្រុមហ៊ុន គិរីអភិវឌ្ឍន៍ សម្រាប់គោលដៅសម្បទានដីសេដ្ឋកិច្ច និងប័ណ្ណសម្គាល់សិទ្ធកាន់កាប់អចលនវត្ថុចំនួន ០៣ប័ណ្ណ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦ របស់មន្ទីររៀបចំដែនដី នគររូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តរតនគិរី។

**មាត្រា២៖**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតនៅក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់បទប្បញ្ញត្តិពាក់ព័ន្ធ និងគោលការណ៍កំណត់របស់រាជរដ្ឋាភិបាល។

**មាត្រា៣៖**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤៖**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តរតនគិរី ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា៤
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com

# គំនូសបង្ហាញទីតាំងដីស្នើសុំចុះបញ្ជីជាឯកជនរបស់រដ្ឋ ក្នុងក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ឌី អេតិចឡង់

ស្ថិតនៅឃុំភ្នំកុក ស្រុកវើនសៃ ខេត្តរតនគិរី

**សំគាល់**

- ចំណុចព្រំដី
- ព្រំក្រុមហ៊ុន សម្បទានដីសេដ្ឋកិច្ច
- ដីស្នើសុំ ពាក្យសុំ ( ៦៦០.៨៨ ហ.ត )
- តំបន់ទ្រនាប់អូរ ( ៨៥.៧៥ ហ.ត )
- ដីប្រជាពលរដ្ឋ ( ៦.៩៧ ហ.ត )
- តំបន់ព្រៃក្រាស់ ( ២៨.៤៦ ហ.ត )
- តំបន់ប្រសាម ( ៧៧.៣៧ ហ.ត )
- ពី០១ ( ៧.៣០ ហ.ត )

0 0.5

តារាងនិយាមកាចំណុចព្រំដី ជាកម្មវត្ថុនៃសម្បទានដីសេដ្ឋកិច្ច
ឃុំភ្នំកុក ស្រុកវើនសៃ ខេត្តរតនគិរី

Projection: UTM, Zone 48N; Datum WGS 84

| Point ID | Northing (m) | Easting (m) |
|---|---|---|
| A | 1532600.503 | 698356.820 |
| B | 1533937.960 | 698255.014 |
| C | 1534373.396 | 698003.684 |
| D | 1534837.324 | 697371.581 |
| E | 1535918.608 | 699015.986 |
| F | 1535914.230 | 700035.510 |
| G | 1534187.505 | 700560.818 |
| H | 1533865.506 | 701506.818 |
| I | 1532022.938 | 701325.263 |
| J | 1533192.504 | 699354.819 |
| K | 1533197.503 | 699012.820 |




រតនគិរី, ថ្ងៃទី...... ខែ...... ឆ្នាំ២០១៧
ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តរតនគិរី

ធីម_ស៊ីណារ៉ាត

បានឃើញ និងឯកភាព
រតនគិរី, ថ្ងៃទី...០៤... ខែ.ធ្នូ........ ឆ្នាំ២០១៧
អភិបាលនៃគណៈអភិបាលខេត្តរតនគិរី

ថង សាវុន

www.pheakdeylaw.com

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់**

**និងសុរិយោដី ខេត្តរតនគិរី**

លេខ: ០៤៧/១៧

**សូមគោរពជូន**

**ឯកឧត្តមអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត**

**កម្មវត្ថុ** ÷ របាយការណ៍ស្តីពីលទ្ធផលក្រុមការងារចុះវាស់វែង និងសិក្សាផលប៉ះពាល់ក្នុងទីតាំងសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន **គីរី អភិវឌ្ឍន៍** ។

**យោង** ÷ របាយការណ៍ស្តីពីការកំណត់ព្រំ និងវាស់វែងដី ដើម្បីចុះបញ្ជីដី នៃដីឯកជនរបស់រដ្ឋ ក្នុងដីសម្បទានសេដ្ឋកិច្ច ក្រុមហ៊ុន គីរីអភិវឌ្ឍន៍។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមគោរពរាយការណ៍ជូន **ឯកឧត្តមអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត** មេត្តាជ្រាបថា: អនុវត្តតាមលិខិតបង្គាប់ការរបស់សាលាខេត្តរតនគិរី ដោយមានការចូលរួមពីមន្ទីរ ស្ថាប័នពាក់ព័ន្ធ ក្រុមការងារដីរដ្ឋថ្នាក់ស្រុក អាជ្ញាធរដែនដី ប្រជាពលរដ្ឋ ក្រុមការងារបានចុះទៅដល់ទីតាំងសម្បទានដីសេដ្ឋកិច្ចជាក់ស្តែងចុចយកចំណុចនិយាមកា បង្គោលព្រំដីនិមួយៗ ពិនិត្យវាស់វែងផលប៉ះពាល់ដីស្រែ-ចំការ និងផលប៉ះពាល់ផ្សេងៗទៀត ដោយប្រើប្រាស់ឧបករណ៍ GPS Garmin 62s។

លទ្ធផលនៃការវាស់វែង មន្ទីរបានរៀបចំប្រជុំក្រុមការងារវាលដើម្បីពិនិត្យ ពិភាក្សា ដោយបានទទួលបានលទ្ធផលដូចខាងក្រោម ៖

| តារាងនិយាមកា ចំណុចព្រំដី ជាកម្មវត្ថុនៃ សម្បទានដីសេដ្ឋកិច្ច | | |
|---|---|---|
| ឃុំភ្នំកុក ស្រុកវើនសៃ ខេត្តរតនគិរី | | |
| Projection UTM, Zone 48N; Datum WGS 1984 | | |
| Point ID | Northing (m) | Easting (m) |
| A | 1532600.503 | 698356.820 |
| B | 1533937.960 | 698255.014 |
| C | 1534373.396 | 698003.684 |
| D | 1534837.324 | 697371.581 |
| E | 1535918.608 | 699015.986 |
| F | 1535914.230 | 700035.510 |
| G | 1534187.505 | 700560.818 |

www.pheakdeylaw.com

| | | |
|---|---|---|
| H | 1533865.506 | 701506.818 |
| I | 1532022.938 | 701325.263 |
| J | 1533192.504 | 699354.819 |
| K | 1533197.503 | 699012.820 |

ទំហំផ្ទៃដី នៃផលប៉ះពាល់ និងក្បាលដីស្នើសុំចុះបញ្ជីដី

| ប្រភេទដី | ទំហំ (ហិកតា) |
|---|---|
| តំបន់ព្រៃក្រាស់ៗ | ២៤,៤៦ |
| តំបន់ទ្រនាប់អូរ | ៨៥,៧៩ |
| ដីប្រជាពលរដ្ឋតាមបទបញ្ជា០១ របស់រាជរដ្ឋាភិបាល | ៧,៣០ |
| ដីប្រជាពលរដ្ឋផ្សេងទៀត | ៦,៥៧ |
| តំបន់ប្រសាទ | ៧៧,៣៧ |
| ផ្ទៃដីដែលមិនបានដាំដុះ | ៨០,០១ |
| ផ្ទៃដីស្នើសុំចុះបញ្ជី | ៦៦០,៩៨ |

ដូច្នេះផ្ទៃដីឯកជនរបស់រដ្ឋ ដែលស្នើសុំចុះបញ្ជីដី ក្នុងសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុន **គីរី អភិវឌ្ឍន៍** មានចំនួន ០៣ ក្បាលដី ដែលមានទំហំសរុប **៦៦០,៩៨** ហិកតា។

អាស្រ័យដូចបានគោរពជំរាបជូនខាងលើ សូម **ឯកឧត្តមអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

រតនគិរី, ថ្ងៃទី............ ខែ............ ឆ្នាំ២០១៧

**មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តរតនគិរី**

ទឹម សុំណារ៉ាត

**បានឃើញ និងឯកភាព**

**អភិបាលខេត្ត និងជាប្រធានអង្គប្រជុំ**

**ថង សាវុន**